# វិជ្ជា៨ ប្រការ

ក្នុងអត្ថបទមុនយើងបានស្គាល់ពីវិជ្ជា៣ របស់ព្រះសម្មាសម្ពុទ្ធរួចហើយ ឥឡូវនេះសូមស្វែងយល់អំពីវិជ្ជាប្រាំបីប្រការដូចតទៅ:

១- វិបស្សនាញាណ ពិចារណាឃើញរូបនិងនាម។ សំដៅយកប្រាជ្ញាសម្រាប់ពិចារណាឃើញច្បាស់នូវបញ្ចក្ខន្ធ ព្រមទាំងការញែកបញ្ចក្ខន្ធចេញជារូប ជានាមដោយចំណែកៗ និងការឃើញច្បាស់នូវធម៌ជាបច្ច័យរបស់នាមនិងរូប។

២- មនោមយិទ្ធិ ឫទ្ធិដែលសម្រេចដោយចិត្ត ។ សំដៅយកឫទ្ធិដែលកើតឡើងបានដោយអំណាចចិត្តគឺថា បើចិត្តចង់និម្មិតកាយរបស់ខ្លួនពីមុនឲ្យឃើញទៅជាកាយដទៃវិញ ដូចជាគេដកបណ្តូលស្មៅយ៉ាប្លងចេញពីទងស្មៅយ៉ាប្លង ឬដូចជាគេហូតដាវចេញពីស្រោម។ មួយទៀតឫទ្ធិរបស់ចិត្តដែលបានអប់រំល្អហើយ ជាហេតុឲ្យភ្លៀវភ្លា អង់អាច គិតការអ្វីបានដូចចិត្តគ្រប់យ៉ាងមិនមានការទើសទាក់សល់ជំពាក់។

៣- ឥទ្ធិវិធ: សំដែងឫទ្ធិបាន។ សំដៅយកការសំដែងឫទ្ធិផ្សេងៗបាន ដែលហួសវិស័យរបស់ជនសាមញ្ញ ដូចយ៉ាងមនុស្សម្នាក់អាចនិម្មិតឲ្យទៅជាច្រើននាក់បានដើរពាន់កាត់គ្រឿងបិទបាំង ដូចជាជញ្ជាំងឬកំពែងក៏បាន មុជក្នុងដីដូចមុជក្នុងទឹកក៏បាន ដើរលើទឹកដូចដើរលើដីក៏បាន ហោះទៅលើអាកាសដូចសត្វបក្សីហើរក៏បាន ស្ទាបអង្អែលព្រះអាទិត្យព្រះចន្ទ័ដោយដៃក៏បាន។

៤- ទិព្វសោត: ត្រចៀកទិព្វ។ សំដៅយកការស្តាប់សំឡេងក្នុងទីជិតឆ្ងាយបាន ទោះបីជាសំឡេងមនុស្សឬជាសំឡេងទេវតា ជាត្រចៀកកន្លងហួសវិស័យនៃត្រចៀកសាមញ្ញជន។

៥- ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តអ្នកដទៃបាន។ សំដៅយកការទាយចិត្តគំនិតរបស់អ្នកដទៃដែលត្រិះរិះគិតទៅរកហេតុណាមួយក៏អាចដឹងបានដោយការកំណត់អធិដ្ឋានចិត្តានុភាព របស់ខ្លួនទៅស្ទាក់ដេញតាមរកចិត្តគំនិតរបស់បុគ្គលដទៃដោយ ចិត្តដ៏បរិសុទ្ធរបស់ខ្លួនដូចមានសេចក្តីដឹងថាចិត្តរបស់បុគ្គលនោះ ៗបរិសុទ្ធឬសៅហ្មងជាដើម។

៦- បុព្វេនិវាសានុស្សតិញ្ញាណ ញាណគឺការរលឹកឃើញនូវខន្ធបញ្ចកៈ(ខន្ធ៥) ក្នុងជាតិមុន។ ការដឹងនូវជាតិ គឺការរលឹកឃើញនូវខន្ធបញ្ចកៈដែលធ្លាប់កើត ធ្លាប់នៅក្នុងភពមុនបាន គឺរលឹកឃើញ ជាតិថយក្រោយក្នុងកាលដែលកន្លងទៅហើយ តាំងអំពីមួយជាតិ ពីរជាតិ បីជាតិ រហូតដល់អនេកជាតិថា "ក្នុងកាលនោះអាត្មាអញបានកើតក្នុងទីនោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ មានសុខទុក្ខយ៉ាងនេះ មានអាយុ ប៉ុណ្ណេះៗជាដើម។ លុះច្យុតអំពីជាតិនោះហើយ ក៏ទៅកើតក្នុងទីនោះៗ លុះមកអំពីទីនោះក៏មកកើតក្នុងទីនេះ"។ ការយល់ធ្លុះធ្លាយឃើញព្រឹត្តិការណ៍របស់ជាតិក្នុងកាលមុនដូច្នេះ ទើបឈ្មោះថា "បុព្វេនិវាសានុស្សតិញ្ញាណ" គឺឃើញការវិលកើតវិលស្លាប់តាមយថាកម្មរបស់សត្វ។

៧- ចុតូបបាតញ្ញាណ ញាណក្នុងការកំណត់ឃើញនូវចុតិនិងបដិសន្ធិនៃពួកសត្វ។ ការដឹងច្បាស់នូវចុតិនិងបដិសន្ធិ គឺការឃ្លាតចាកជីវិតនិងការចាប់កំណើតបាន ដោយការឃើញពួកសត្វដែលកំពុងច្យុតក៏មាន កំពុងចាប់កំណើតក៏មាន ដឹងច្បាស់ថា "ពួកសត្វទាំងនោះមានគតិផ្សេងៗគ្នាខ្លះថោកទាប ខ្លះខ្ពង់ខ្ពស់ តាមយថាកម្មរបស់ខ្លួនៗ ដោយអំណាចផលវិបាកនៃការប្រព្រឹត្តរបស់ពួកសត្វ"។ ការដឹងច្បាស់នូវចុតិនិងបដិសន្ធិនៃពួកសត្វដូច្នេះ ទើបឈ្មោះថា "ចុតូបបាតញ្ញាណ"។

៨- អាសវក្ខយញ្ញាណ ញាណក្នុងការធ្វើឲ្យអស់នូវអាសវៈ ។ ការដឹងច្បាស់នូវហេតុជាទីអស់ទៅនៃអាសវៈនោះ បានដល់ការដឹងច្បាស់តាមពិតថា "នេះជាទុក្ខ នេះជាសមុទ័យ (ហេតុឲ្យកើតទុក្ខ) នេះជានិរោធ (ការរលត់ទុក្ខ) នេះជាមគ្គ (ផ្លូវប្រតិបត្តិដើម្បីរំលត់ទុក្ខ) នេះជាអាសវៈ នេះជាហេតុដែលអោយកើតអាសវៈ នេះជាសេចក្តីប្រតិបត្តិដើម្បីឲ្យអស់អាសវៈ" កាលដឹងច្បាស់ដូច្នេះហើយចិត្តក៏រមែងរួចចាកអាសវៈទាំង៤ ប្រការ គឺកាមាសាវៈ ភវាសវៈ ទិដ្ឋាសវៈនិងអវិជ្ជាសវៈ ។ ដឹងច្បាស់ថាជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តចប់ហើយ ករណីកិច្ចរបស់អញបានសម្រេចហើយ កិច្ចដែលត្រូវចម្រើនតទៅទៀតពុំមានឡើយ"។

ទាំងប្រាំបីនេះប្រការនេះហៅថា វិជ្ជា៨ ប្រការ។

សូមអស់លោកអ្នកអនុមោទនា !

ចប់